សូមចូលរួមនៅក្នុងការ
ស្រង់ចំនួនប្រជាជនឆ្នាំ២០០០

លទ្ធផលនៃការស្រង់ចំនួនប្រជាជនឆ្នាំ២០០០
នឹងមានការប៉ះទង្គិចដ៏ខ្លាំង ទៅលើរូបអ្នក
កូនរបស់អ្នក និងតំបន់ជិតខាងរបស់អ្នក

# ការឆ្លើយតបរបស់អ្នកជាការចាំបាច់!

## តើអ្វីទៅជាការស្រង់ចំនួនប្រជាជនឆ្នាំ២០០០?

១០ឆ្នាំម្តង ការិយាល័យស្រង់ចំនួនប្រជាជន ធ្វើការរាប់ចំនួនសារុបនៃប្រជាជននៅក្នុងសហរដ្ឋអាមេរិក។ ការរាប់ចំនួនប្រជាជនលើកក្រោយនេះ ហៅថា "ការស្រង់ចំនួនប្រជាជនឆ្នាំ២០០០ " **"CENSUS 2000"**
ដែលនឹងធ្វើឡើងនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០០។ រដ្ឋាភិបាលផ្នែក ពាណិជ្ជកម្ម និងអង្គការផ្សេងៗ ត្រូវការ ការរាប់ចំនួនប្រជាជនដ៏ពិតប្រាកដ ដើម្បីផ្តល់សេវកម្មចាំបាច់។ ការបំពេញក្រដាសស្រង់ចំនួនប្រជាជន នឹងជួយតំបន់ជិតខាងរបស់អ្នកទទួល អត្ថប្រយោជន៏ និងសេវកម្មផ្សេងៗ។

## តើការស្រង់ចំនួនប្រជាជនអាចប្រើប្រាស់ទៅលើអ្វីខ្លះ?

- ដើម្បីធ្វើការសំរេចពីចំនួនថវិកាដែលសហគមន៏របស់អ្នកនឹងបានទទួលសំរាប់សាលារៀន
- ដើម្បីធ្វើការសំរេចទៅលើទីកន្លែងសំរាប់ស្ពាបនា មន្ទីរពេទ្យ មណ្ឌលថែទាំក្មេង និងផ្លូវថ្នល់
- ដើម្បីធ្វើការសំរេចពីចំនួនតំណាងរាស្ត្រនៅក្នុងរដ្ឋរបស់អ្នក ដែលនឹងបំរើក្នុងផ្នែកតំណាងរាស្ត្រប្រចាំសហរដ្ឋអាមេរិក
- ដើម្បីផ្តល់ថវិកាសំរាប់ផ្នែកហ្វឹកហ្វឺនអាជីវកម្ម និងការខ្ចីថវិកាសំរាប់សិស្ស
- ដើម្បីការពារការប្រកាន់បក្សពួក ទៅលើប្រជាជនភាគតិច ជនពិការ និងជនជរា នៅតាមទីកន្លែងប្រកបអាជីវកម្ម

## តើការរាប់ចំនួនប្រជាជននេះ កើតមានឡើងដោយរបៀបណា?

នៅដើមខែមិនា ឆ្នាំ២០០០ ក្រុមគ្រួសារទាំងអស់ នឹងបានទទួលលិខិតតាមប៉ុស្តិ៍ប្រៃសនីយ៏អំពីការស្រង់ចំនួនប្រជាជន។ លិខិតនេះនឹងអនុញ្ញាត្តិ អោយអ្នកស្នើសុំក្រដាសបំពេញការស្រង់ចំនួនប្រជាជនជាភាសា ចិន កូរ៉េ ថាហ្គាឡុក់(ហ្វីលីពិន) ឬវៀតណាម។ នៅចុងខែមិនា ក្រុមគ្រួសារ ទាំងអស់នៅក្នុងសហរដ្ឋអាមេរិក នឹងទទួលក្រដាសបំពេញចំនួនប្រជាជន តាមរយៈប៉ុស្តិ៍ប្រៃសនីយ៏។ ក្រដាសបំពេញស្រង់ចំនួនប្រជាជន នឹងសួរ សំណួរដូចជា ឈ្មោះ ភេទ អាយុ ការជាប់សាច់ញាត្តិ សញ្ជាត្តិដើម សាសន៏ នៃសមាជិកទាំងអស់នៅក្នុងក្រុមគ្រួសាររបស់អ្នក។

## ការបំពេញក្រដាស !!!

តាមច្បាប់ ចម្លើយដែលអ្នកឆ្លើយនៅក្នុងក្រដាសស្រង់ចំនួនប្រជាជន គឺជាការសម្ងាត់។ ពត៏មានទាំងនោះពុំអាចចែកចាយជាមួយបុគ្គល ឬភ្នាក់ងាររដ្ឋាភិបាល ដូចជាផ្នែកអន្តោប្រវេសន៏ INS ឬផ្នែកបង់ពន្ធដារ IRS បានឡើយ។ ការបំពេញក្រដាសនេះ នឹងជួយផ្តល់ការចំរើន លូតលាស់ នៅក្នុងតំបន់ជិតខាងរបស់អ្នកតែប៉ុណ្ណោះ។

Produced by the National Asian Pacific American Legal Consortium, Washington, DC. January 1999.
Reproduction permitted only with attribution. "Your Response Is Important," Cambodian.